**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨.០១៦.២៨០ សជ.ស.ណ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា ការជ្រើសរើសបុគ្គលិកភេទប្រុស ចំនួន ៣១រូប (ផ្នែកបោះពុម្ព២០រូប ផ្នែកប្រព័ន្ធសុវត្ថិភាព:០៥រូប ផ្នែកម៉ាស៊ីនកាត់:០៤រូប ផ្នែកម៉ាស៊ីនអ៊ុត:០២រូប) តាមរយៈលិខិតជូនដំណឹងលេខ ធ៨.០១៦-១៧៤ សជណ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ត្រូវបានកែសម្រួលលក្ខខណ្ឌអាយុ និងកាលបរិច្ឆេទឈប់ទទួលពាក្យដូចតទៅ៖

១- បេក្ខជនអាចមានអាយុត្រឹម៣០ឆ្នាំ តាមលក្ខខណ្ឌសញ្ញាបត្រនិងជំនាញឯកទេស ដែលធនាគារជាតិនៃកម្ពុជាត្រូវការ សម្រាប់ផ្នែកនីមួយៗខាងលើ។

២- កាលបរិច្ឆេទឈប់ទទួលពាក្យ ត្រូវពន្យារដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង១១:០០ព្រឹក។

បេក្ខជនអាចមកទំនាក់ទំនងសាកសួរព័ត៌មានលម្អិតបន្ថែមទៀត នៅនាយកដ្ឋានបុគ្គលិកនៃធនាគារជាតិនៃកម្ពុជា ដែលមានទីតាំងនៅឡូត៍ ២២-២៤ តាមបណ្តោយមហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ចន្លោះពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ១៥:០០រសៀល រៀងរាល់ថ្ងៃធ្វើការ។

សម្រាប់កាលបរិច្ឆេទ មុខវិជ្ជា និងទីកន្លែងប្រឡង នឹងជូនដំណឹងពេលក្រោយ ។

**ត.ប.ទេសាភិបាល**
**អគ្គលេខាធិការ**

**ស៊ុំ សន្និសិទ្ធ**



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧